ប្រសិនបើអ្នកជ្រើសរើសមិនផ្តល់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកទេ យើងនឹងមិនអាចរៀបចំការថែទាំតាមដានចាំបាច់ណាមួយដែលទារករបស់អ្នកតម្រូវបន្ទាប់ពីការឆ្លុះមើលសោតវិញ្ញាណឡើយ។ យើងក៏នឹងមិនអាចទាក់ទងអ្នកអំពីគម្រោងស្រាវជ្រាវ និងគំនិតផ្តួចផ្តើមនាពេលអនាគតបានផងដែរ។

## សំណួរដែលគេតែងសួរជាញឹកញាប់

### ទារករបស់ខ្ញុំឆ្លើយតបទៅនឹងសំឡេងខ្លាំងៗ - តើពួកគេនៅតែត្រូវការការឆ្លុះមើលសោតវិញ្ញាណទារកទើបនឹងកើត ឬការវាយតម្លៃសោតទស្សន៍ដែរទេ?

ការបាត់បង់សោតវិញ្ញាណគឺកាន់តែស្មុគស្មាញជាងការគ្រាន់តែអាចស្តាប់ឮសំឡេងខ្លាំងៗទៅទៀត។ ទារកភាគច្រើនដែលមានការបាត់បង់សោតវិញ្ញាណ នឹងនៅតែមានប្រតិកម្មចំពោះសំឡេងខ្លាំងៗ។ សំឡេងសំខាន់ៗសម្រាប់ការអភិវឌ្ឍន៍ការនិយាយ និងភាសា គឺសំឡេងទន់ ហើយសំឡេងទាំងនេះពិបាកនឹងធ្វើតេស្តលើទារកដែលទើបនឹងកើតដោយគ្មានឧបករណ៍ឯកទេសនោះឡើយ។

### តើការឆ្លុះមើលសោតវិញ្ញាណទារកទើបនឹងកើតមានសុវត្ថិភាពទេ? តើការឆ្លុះមើលសោតវិញ្ញាណមានហានិភ័យអ្វីខ្លះ?

ការឆ្លុះមើលសោតវិញ្ញាណគឺរហ័ស និងមានសុវត្ថិភាព។ ទារករបស់អ្នកអាចជួបប្រទះនឹងភាពមិនស្រួលមួយរយៈខ្លី នៅពេលឧបករណ៍ភ្ជាប់ត្រចៀកត្រូវបានដកចេញ។ មានហានិភ័យតិចតួចមួយដែលការឆ្លុះមើលសោតវិញ្ញាណអាចមិនកំណត់អត្តសញ្ញាណទារកដែលការស្តាប់ត្រូវការការស៊ើបអង្កេតបន្ថែមទៀត។

### តើមានហានិភ័យអ្វីខ្លះនៃការមិនបានឆ្លុះមើលសោតវិញ្ញាណទារកទើបនឹងកើត? តើមានជម្រើសផ្សេងសម្រាប់ការឆ្លុះមើលសោតវិញ្ញាណទេ?

ហានិភ័យចម្បងនៃការមិនបានឆ្លុះមើលសោតវិញ្ញាណ គឺការពន្យារពេលក្នុងការធ្វើរោគវិនិច្ឆ័យប្រសិនបើទារកមានការបាត់បង់សោតវិញ្ញាណ។ ការធ្វើរោគវិនិច្ឆ័យបានមុនពេល អនុញ្ញាតឱ្យមានជំនួយដំបូងដែលផ្តល់ឱ្យទារកដែលមានការបាត់បង់សោតវិញ្ញាណនូវឱកាសដ៏ល្អបំផុតដែលអាចធ្វើទៅបាន ក្នុងការអភិវឌ្ឍន៍ជំនាញទំនាក់ទំនង។ មិនមានជម្រើសផ្សេងទៀតសម្រាប់ការឆ្លុះមើលសោតវិញ្ញាណទារកទើបនឹងកើតនោះទេ។

## សោតវិញ្ញាណអាចផ្លាស់ប្តូរតាមពេលវេលា

ការបាត់បង់សោតវិញ្ញាណអាចវិវឌ្ឍទៅតាមពេលវេលា ដូច្នេះវាមានសារៈសំខាន់ក្នុងការយកចិត្តទុកដាក់លើសោតវិញ្ញាណរបស់ទារកអ្នកនៅពេលពួកគេធំឡើង។ និយាយទៅកាន់គិលានុបដ្ឋាកសុខភាពម្តាយ និងទាររបស់អ្នក ឬវេជ្ជបណ្ឌិតប្រចាំគ្រួសារ ប្រសិនបើអ្នកមានសំណួរ ឬកង្វល់ណាមួយអំពីសោតវិញ្ញាណរបស់ទារកអ្នក។

## តើមានសំណួរ ឬកង្វល់ណាមួយទេ?

**ទាក់ទង VIHSP**

ពិភាក្សាជាមួយអ្នកឆ្លុះមើលសោតវិញ្ញាណ VIHSP

អ្នកគ្រប់គ្រងតំបន់ VIHSP

**ការិយាល័យកណ្តាល VIHSP**

Royal Children’s Hospital (មន្ទីរពេទ្យកុមារទីក្រុងមែលប៊ិន)
Centre for Community Child Health
(មជ្ឈមណ្ឌលសុខភាពកុមារសហគមន៍)

50 Flemington Road Parkville
Victoria 3052 Australia
ទូរសព្ទ +61 3 9345 4941
អ៊ីមែល email.vihsp@rch.org.au
www.rch.org.au/vihsp

The Royal Children’s Hospital Melbourne



# ការឆ្លុះមើលសោតវិញ្ញាណរបស់ទារកអ្នក



Victorian Infant Hearing Screening Program

# ការឆ្លុះមើលសោតវិញ្ញាណរបស់ទារកអ្នក

## ហេតុអ្វីការឆ្លុះមើលសោតវិញ្ញាណរបស់ទារកទើបនឹងកើតមានសារៈសំខាន់?

ការឆ្លុះមើលសោតវិញ្ញាណទារកទើបនឹងកើត គឺជាការត្រួតពិនិត្យសុខភាពជាប្រចាំដែលទារករបស់អ្នកនឹងមានក្រោយពេលកើតមក។ វាឥតគិតថ្លៃ ហើយការត្រួតពិនិត្យសោតវិញ្ញាណរបស់ទារកអ្នកគឺរហ័ស។ វាត្រូវបានផ្តល់ដោយកម្មវិធីការឆ្លុះមើលសោតវិញ្ញាណ (ពិនិត្យត្រចៀក) ទារករដ្ឋវិចថូរៀ (VIHSP) ដែលគ្រប់គ្រងដោយមន្ទីរពេទ្យកុមារ Royal Children's Hospital។ ការបាត់បង់សោតវិញ្ញាណប្រហែលជាមិនសូវច្បាស់ទេក្នុងប៉ុន្មានសប្តាហ៍ដំបូងនៃជីវិត ហើយអាចប៉ះពាល់ដល់ការអភិវឌ្ឍន៍ក្នុងការនិយាយ និងភាសា។ ការរកឃើញទាន់ពេលមានន័យថា ទារកដែលមានការបាត់បង់សោតវិញ្ញាណអាចចាប់ផ្តើមជីវិតរស់នៅបានល្អបំផុត។

## តើការឆ្លុះមើលសោតវិញ្ញាណទារកទើបនឹងកើតត្រូវបានធ្វើដោយរបៀបណា?

ដោយមានការយល់ព្រមរបស់អ្នក អ្នកឆ្លុះមើលសោតវិញ្ញាណនឹងបិទបន្ទះចាប់សញ្ញាតូចមួយនៅលើថ្ងាស ថ្ពាល់ និងខ្នងរបស់ទារកអ្នក។ ឧបករណ៍ឆ្លុះមើលសោតវិញ្ញាណនឹងចាក់សំឡេងស្រទន់ចូលទៅក្នុងត្រចៀករបស់ទារកអ្នកតាមរយៈឧបករណ៍ភ្ជាប់ (កាសស្តាប់ទន់) ដាក់នៅលើត្រចៀកនីមួយៗ។ ឧបករណ៍ចាប់សញ្ញារកឃើញការឆ្លើយតបរបស់ទារកអ្នកចំពោះសំឡេង។

ការឆ្លុះមើលមិនមានការឈឺចាប់ទេ ហើយជាធម្មតានឹងមិនធ្វើឱ្យទារករបស់អ្នកម៉ូរម៉ៅនៅឡើយ។ វាត្រូវចំណាយពេលតិចជាងប្រាំនាទី ប្រសិនបើទារករបស់អ្នកម៉ូរម៉ៅ ឬដេកលក់ ហើយបន្ទប់មានភាពស្ងប់ស្ងាត់។ អ្នកអាចបីពរ ឬបំបៅទារកដោយទឹកដោះម្តាយក្នុងអំឡុងពេលឆ្លុះមើល។

## តើពេលណាទើបទារករបស់ខ្ញុំមានការឆ្លុះមើលសោតវិញ្ញាណទារកទើបនឹងកើត?

យើងព្យាយាមឆ្លុះមើលទារកភ្លាមៗក្រោយពេលកើតមក ដរាបណាពួកគេមានសុខភាពល្អ និងសុខស្រួល។ ប្រសិនបើទារករបស់អ្នកបានស្ថិតនៅក្នុងមន្ទីរព្យាបាលដើម្បីសង្គ្រោះបន្ទាន់ទារកទើបនឹងកើត ឬកន្លែងថែទាំទារកពិសេស ឬកើតមកមុន 34 សប្តាហ៍ទេ យើងនឹងរង់ចាំធ្វើការឆ្លុះមើលនៅពេលណាទារករបស់អ្នកមានសុខភាពល្អ ឬជិតរួចរាល់ដើម្បីត្រឡប់ទៅផ្ទះវិញពីមន្ទីរពេទ្យ។

## ចុះបើទារករបស់ខ្ញុំមិនអាចទៅឆ្លុះមើលនៅមន្ទីរពេទ្យវិញ?

ទារកមួយចំនួនដែលមិនទាន់បានធូរស្រាល ឬត្រូវបានអនុញ្ញាតឱ្យចាកចេញពីការព្យាបាលមុនពេល អាចនឹងមិនទទួលបានការឆ្លុះមើលសោតវិញ្ញាណទារកទើបនឹងកើត មុនពេលពួកគេចាកចេញពីមន្ទីរពេទ្យ។ ប្រសិនបើរឿងនេះកើតឡើង យើងនឹងទាក់ទងមកអ្នកដើម្បីរៀបចំការណាត់ជួបមួយសម្រាប់អ្នកជំងឺដែលមិនសម្រាកព្យាបាលនៅមន្ទីរពេទ្យ។

## តើខ្ញុំនឹងដឹងពីលទ្ធផលនៃការឆ្លុះមើលសោតវិញ្ញាណដោយរបៀបណា?

អ្នកនឹងត្រូវបានផ្តល់លទ្ធផលភ្លាមៗ នៅពេលការលុះមើលបានបញ្ចប់។ លទ្ធផល*ជាប់*មានន័យថា មានការឆ្លើយតបយ៉ាងច្បាស់លាស់ចំពោះការលុះមើល ហើយមិនចាំបាច់លុះមើលបន្ថែមទៀតទេ។ ប្រសិនបើមិនមានការឆ្លើយតបច្បាស់លាស់ទេ ការលុះមើលសោតវិញ្ញាណរបស់ទារកទើបនឹងកើតនឹងត្រូវធ្វើឡើងម្តងទៀតក្នុងចំនួនដ៏កំណត់។ ប្រសិនបើការលុះមើលសោតវិញ្ញាណចុងក្រោយរបស់ទារកអ្នកមិនបង្ហាញការឆ្លើយតបច្បាស់លាស់ទេ ពួកគេនឹងត្រូវបានបញ្ជូនបន្តទៅអ្នកជំនាញផ្នែកសោតទស្សន៍សម្រាប់ការធ្វើតេស្តលម្អិត។ អ្នកគ្រប់គ្រងតំបន់ VIHSP និងសេវាកម្មជំនួយដំបូង VIHSP នឹងទាក់ទងមកអ្នកដើម្បីពិភាក្សាអំពីការបញ្ជូនបន្តនេះ។

យើងនឹងកត់ត្រាលទ្ធផលនៃការលុះមើលសោតវិញ្ញាណរបស់ទារកអ្នកនៅក្នុង *សុខភាពរបស់ខ្ញុំ (My Health), កំណត់ត្រាការរៀនសូត្រ និងការអភិវឌ្ឍន៍* (សៀវភៅពណ៌បៃតង) និងនៅក្នុងមូលដ្ឋានទិន្នន័យ VIHSP។

## តើព័ត៌មានអំពីខ្ញុំ និងទារករបស់ខ្ញុំត្រូវបានកត់ត្រា និងប្រើប្រាស់យ៉ាងដូចម្តេច?

មូលដ្ឋានទិន្នន័យ VIHSP ត្រូវបានប្រើដើម្បីតាមដាន និងវាយតម្លៃ VIHSP ព្រមទាំងដើម្បីភ្ជាប់ទារក និងក្រុមគ្រួសាររបស់ពួកគេជាមួយនឹងសេវាកម្មនានា។ VIHSP ប្រមូល និងប្រើប្រាស់ព័ត៌មានអំពីអ្នក និងទារករបស់អ្នកស្របតាមគោលការណ៍ឯកជនភាពសុខភាពដែលមាននៅក្នុង*ច្បាប់ស្តីពីកំណត់ត្រាសុខភាព ឆ្នាំ 2001* និងគោលការណ៍ឯកជនភាពព័ត៌មាននៅក្នុង*ច្បាប់ឯកជនភាព និងការការពារទិន្នន័យ ឆ្នាំ 2014*។

ច្បាប់ទាំងនេះក៏គ្របដណ្តប់លើការប្រើប្រាស់ព័ត៌មានសម្រាប់ការវាយតម្លៃ ការអប់រំ និងការស្រាវជ្រាវផងដែរ។

VIHSP ប្តេជ្ញារក្សាព័ត៌មានដែលប្រមូលបានជាសម្ងាត់ និងមានសុវត្ថិភាពពីការចូលប្រើប្រាស់ដោយគ្មានការអនុញ្ញាត ឬការបាត់បង់។

ដើម្បីធានាថាទារករបស់អ្នកត្រូវបានភ្ជាប់ជាមួយនឹងសេវាកម្ម និងការព្យាបាលបានត្រឹមត្រូវ ព័ត៌មានដូចជាព័ត៌មានលម្អិតអំពីកំណើត ព័ត៌មានលម្អិតទំនាក់ទំនង និងការឆ្លុះមើល ឬលទ្ធផលសោតទស្សន៍អាចត្រូវបានចែករំលែករវាង VIHSP និងអ្នកជំនាញផ្សេងទៀតរួមមាន៖

- អ្នកជំនាញផ្នែកសោតទស្សន៍
- វេជ្ជបណ្ឌិត
- គិលានុបដ្ឋាកសុខភាពម្តាយ និងទារក
- សេវាកម្មអន្តរាគមន៍កុមារវ័យតូច
- អ្នកជំនាញផ្នែកសុខភាព និងអប់រំផ្សេងទៀត។

VIHSP អាចប្រើប្រាស់ព័ត៌មានរបស់អ្នកសម្រាប់គោលបំណងនៃការវាយតម្លៃ ការអប់រំ និងការស្រាវជ្រាវ។ អ្នកប្រហែលជាត្រូវបានទាក់ទងអំពីគម្រោងនានានៅពេលអនាគត។ អ្នកអាចជ្រើសរើសថាតើអ្នកចង់ស្វែងយល់បន្ថែមអំពីគម្រោងទាំងនោះនៅពេលនោះឬអត់។ ប្រសិនបើគម្រោងពាក់ព័ន្ធនឹងការស្រាវជ្រាវ គម្រោងទាំងនេះត្រូវបានធ្វើឡើងដោយយោងតាមសេចក្តីថ្លែងការណ៍ថ្នាក់*ជាតិស្តីពីការប្រតិបត្តិផ្នែកសីលធម៌នៅក្នុងការស្រាវជ្រាវមនុស្ស*។

សូមនិយាយទៅកាន់អ្នកគ្រប់គ្រងតំបន់ VIHSP ប្រសិនបើអ្នកចង់ដឹងបន្ថែមអំពីអ្វីដែលកើតឡើងចំពោះព័ត៌មានដែលបានប្រមូលដោយ VIHSP។ អ្នកអាចចូលប្រើប្រាស់ ឬកែប្រែព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកដោយទាក់ទងការិយាល័យសេរីភាពដើម្បីទទួលបានព័ត៌មាននៅមន្ទីរពេទ្យកុមារ Royal Children's Hospital៖ **www.rch.org.au/foi**